**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៧៩៦ សហវ.ប្រក.ស.គ.ស

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ ០០៧ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ ដែលសរសេរជាអក្សរកាត់ថា **គ.ស.ស**. ដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន១រូប ប្រធាន
- អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អនុប្រធានប្រចាំការ
- អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម ចំនួន១រូប អនុប្រធាន
- អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ ចំនួន១រូប អនុប្រធាន
- តំណាងអាជ្ញាធរសវនកម្មជាតិ ចំនួន១រូប សមាជិក
- តំណាងក្រុមប្រឹក្សានីតិកម្ម ចំនួន១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានរតនាគារជាតិ ចំនួន១រូប សមាជិក
- តំណាងនិយ័តករគណនេយ្យនិងសវនកម្ម ចំនួន២រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល ចំនួន១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ចំនួន១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានពន្ធដារ ចំនួន១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចំនួន១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានថវិកា ចំនួន១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ចំនួន១រូប សមាជិក
- តំណាងអគ្គាធិការដ្ឋាន ចំនួន១រូប សមាជិក
- តំណាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន១រូប សមាជិក
- តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន១រូប សមាជិក
- តំណាងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន១រូប សមាជិក
- តំណាងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ចំនួន៣រូប សមាជិក។

សមាសភាពជាក់ស្តែងរបស់ **គ.ស.ស**. ដែលជាតំណាងមកពីបណ្តាស្ថាប័ន អង្គភាពដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទីភារកិច្ចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន **គ.ស.ស**. ផ្អែកតាមសេចក្តីស្នើរបស់ប្រធានស្ថាប័ន អង្គភាពសាមី។

ប្រធាន **គ.ស.ស**. អាចស្នើសុំបន្ថែម ឬ បន្ថយសមាសភាពសមាជិក តាមការចាំបាច់។

**គ.ស.ស.** អាចអញ្ជើញអ្នកជំនាញ និងតំណាងភាគីពាក់ព័ន្ធ ដើម្បីចូលរួមផ្តល់យោបល់លើប្រធានបទនានាពាក់ព័ន្ធនឹងគណនេយ្យសាធារណៈ និងការអនុវត្តមុខងារភារកិច្ចរបស់ខ្លួនបាន។

**ប្រការ២.-**

**គ.ស.ស.** មានមុខងារភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវអំពីឧត្តមានុវត្តន៍ជាអន្តរជាតិនៃស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ
- ពិនិត្យ និងតាមដានការអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពលម្អិតដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១
- ពិនិត្យ និងផ្តល់យោបល់ ក្នុងទិដ្ឋភាពបច្ចេកទេសនិងការអនុវត្តជាក់ស្តែង ទៅលើសេចក្តីព្រាងស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈដែលបានរៀបចំ
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយនិងនីតិវិធីគណនេយ្យ គាំទ្រដល់ការអនុវត្តស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ
- សិក្សាស្រាវជ្រាវ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសលើបញ្ហាប្រឈម និងស្នើដំណោះស្រាយ និង/ឬ គោលការណ៍ណែនាំក្នុងការអនុវត្តស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ និងលើកសំណើជូន **ន.គ.ស.**
- ពិនិត្យ និងផ្តល់យោបល់លើអត្ថបទសេចក្តីព្រាងស្តង់ដាគណនេយ្យដែលបានបកប្រែជាភាសាខ្មែរ
- អនុវត្តមុខងារភារកិច្ចមួយចំនួនទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ៣.-**

នាយកដ្ឋានបច្ចេកទេសនៃ **ន.គ.ស.** ជាលេខាធិការដ្ឋានរបស់ **គ.ស.ស.** និងដើរតួនាទីជាសេនាធិការរដ្ឋបាល និងបច្ចេកទេស។ ប្រធាន ឬ អនុប្រធាននាយកដ្ឋានបច្ចេកទេស ជាប្រធានលេខាធិការដ្ឋាន និងមានអនុប្រធាននិងសមាជិកមួយចំនួន។ ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាន ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទីភារកិច្ចដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ស.**។

**ប្រការ៤.-**

អនុប្រធានប្រចាំការ អនុប្រធាន និងសមាជិក នៃ **គ.ស.ស.** ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ លិខិតអញ្ជើញ របៀបវារៈ និងឯកសារពាក់ព័ន្ធ ត្រូវផ្ញើជូនប្រធាន អនុប្រធានប្រចាំការ អនុប្រធាន និងសមាជិក យ៉ាងហោចណាស់ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទកិច្ចប្រជុំ វៀរលែងតែកិច្ចការបន្ទាន់។ ក្នុងករណីអវត្តមានប្រធាន **គ.ស.ស.** ត្រូវផ្ទេរសិទ្ធិជូនអនុប្រធានប្រចាំការ ដើម្បីដឹកនាំប្រជុំជំនួស ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពនៃការអនុវត្តមុខងារភារកិច្ចរបស់ **គ.ស.ស.**។

កិច្ចប្រជុំរបស់ **គ.ស.ស.** អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយ នៃសមាជិកទាំងអស់។ ក្នុងករណីដែលកិច្ចប្រជុំលើកទីមួយមិនអាចប្រព្រឹត្តទៅបានដោយមូលហេតុខ្វះកូរ៉ុម ប្រធានអាចកោះអញ្ជើញប្រជុំម្តងទៀតជាលើកទីពីរបាន ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំលើកទីមួយ។ ការប្រជុំលើកទីពីរនេះ មិនតម្រូវឱ្យមានសមាជិកគ្រប់ចំនួនកូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានមិនបានប្រជុំតាមការអញ្ជើញលើកទីមួយប៉ុណ្ណោះ។

សេចក្ដីសម្រេចរបស់ **គ.ស.ស.** អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងជាពីរស្មើគ្នា សំឡេងរបស់ប្រធាននៃកិច្ចប្រជុំមានឧត្តមានុភាព។

**ប្រការ៥._**

រាល់កិច្ចប្រជុំរបស់ **គ.ស.ស.** ត្រូវមានកំណត់ហេតុ។

សេចក្ដីសម្រេចរបស់ **គ.ស.ស.** ត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយប្រធាននៃកិច្ចប្រជុំ និងលេខាកត់ត្រា។ កំណត់ហេតុនេះត្រូវផ្ញើជូនប្រធាន អនុប្រធានប្រចាំការ អនុប្រធាន និងសមាជិកទាំងអស់នៃ **គ.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ។

**គ.ស.ស.** ត្រូវធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពការងារជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ៦._**

**គ.ស.ស.** ប្រើប្រាស់ថវិការបស់ **ន.គ.ស.** ដើម្បីបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ស្របតាមប្រកាសនេះ។

**គ.ស.ស.** អាចប្រើប្រាស់ត្រារបស់ **ន.គ.ស.** ដើម្បីដំណើរការការងាររបស់ខ្លួនបាន។

**ប្រការ៧._**

ប្រកាសលេខ ៧៧៤ សហវ.ប្រក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការបង្កើតនិងការតែងតាំងសមាសភាពក្រុមការងារបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គាធិការ អគ្គសវនករ នាយកវិទ្យាស្ថាន ប្រធានអង្គភាពដូចមានចែងក្នុងប្រការ១ និងគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ គ.ស.២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព និងសមាសភាពពាក់ព័ន្ធ
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ